## រឿងទី៨៖
## អ្នកស្រុកសាម៉ារីម្នាក់មានចិត្តសប្បុរស

**ខគម្ពីរ៖**
**លូកា១០៖៣៧**

អ្នកនោះឆ្លើយថា គឺអ្នក១ដែលមានចិត្តអាណិតដល់គាត់នោះឯង ដូច្នេះ ព្រះយេស៊ូវមានព្រះបន្ទូលថា ទៅចុះ ចូរអ្នកប្រព្រឹត្តបែបយ៉ាងដូច្នោះដែរ។

មានបណ្ឌិតខាងវិន័យម្នាក់ ចង់ល្បងលព្រះយេស៊ូ។ «តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានជីវិតអស់កល្ប?»

ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «តើក្នុងគម្ពីរវិន័យមានចែងទុកមកដូចម្ដេចខ្លះ?»

គាត់ទូលឆ្លើយទៅព្រះយេស៊ូថា៖ «ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឱ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីកម្លាំង និងអស់ពីប្រាជ្ញា ហើយត្រូវស្រឡាញ់អ្នកជិតខាង ឱ្យបានដូចស្រឡាញ់ខ្លួនឯងដែរ»។

ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «លោកឆ្លើយត្រឹមត្រូវល្អណាស់ សុំធ្វើដូច្នេះទៅ នោះលោកនឹងមានជីវិតអស់កល្បជាមិនខាន»។

ប៉ុន្តែ បណ្ឌិតខាងវិន័យនោះ ចង់បង្ហាញថាខ្លួនជាមនុស្សត្រឹមត្រូវ  ក៏បានសួរព្រះយេស៊ូថា៖ «បើអ៊ីចឹង តើនរណាជាអ្នកជិតខាងរបស់ខ្ញុំ?»

ព្រះយេស៊ូក៏បាននិទានរឿងមួយទៅកាន់គាត់។

មានបុរសម្នាក់ធ្វើដំណើរចុះពីក្រុងយេរូសាឡិមឆ្ពោះទៅក្រុងយេរីខូ។

គាត់ធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ពួកចោរ វាដោះសំលៀកបំពាក់របស់គាត់ រួចវាយដំស្ទើរតែនឹងស្លាប់ រួចនាំគ្នារត់បាត់អស់ទៅ។

បុរសនោះរងរបួសជាទម្ងន់ មិនអាចក្រោកឡើងបានឡើយ។

ពេលនោះ ស្រាប់តែឮសំឡេងសម្រិបជើង។

សំឡេងសម្រិបជើងនោះ គឺជាសំឡេងសម្រិបជើងរបស់បូជាចារ្យជាអ្នកថ្វាយយញ្ញបូជាដល់ព្រះ។

ប៉ុន្តែ ពេលបូជាចារ្យឃើញបុរសនោះ គាត់បានធ្វើជាមើលមិនឃើញ ក៏ដើរវាងហួសទៅ។

មួយសន្ទុះក្រោយមក ក៏បានឮសម្រិបជើងនរណាម្នាក់ទៀត។ គាត់គឺជាមនុស្សម្នាក់ពីក្រុមលេវីជាអ្នកជួយការងារបូជាចារ្យនៅក្នុងព្រះវិហារ។

បុរសលេវីនោះ ក៏បានឃើញបុរសនោះដែរ តែគាត់បានធ្វើជាមិនឃើញ ហើយក៏ដើរវាងហួសទៅ។

បុរសនោះ កាន់តែអស់កម្លាំងទៅៗ។ ប៉ុន្តែ បន្តិចក្រោយមក ក៏ឮសម្រិបជើងរបស់នរណាម្នាក់ទៀត។

គឺជាបុរសម្នាក់កំពុងជិះលា។ គាត់គឺជាសាសន៍សាម៉ារី។




31



កាលគ្រានោះ ជនជាតិអ៊ីស្រាអែលមើលរំលង មិនឱ្យតម្លៃសាសន៍សាម៉ារីទេ។
បុរសនោះកាន់តែអស់កម្លាំងទៅៗ គាត់ស្ទើរតែបោះបង់ជីវិតទៅហើយ។
ប៉ុន្តែ មានរឿងដ៏ភ្ញាក់ផ្អើលមួយបានកើតឡើង។ នោះគឺ បុរសសាសន៍សាម៉ារីនោះ បានលើកបុរសនោះដាក់លើខ្នងលា។
សាសន៍សាម៉ារីនោះ បានជូតឈាមយ៉ាងប្រុងប្រយ័ត្ន។ គាត់បានលាបថ្នាំ ហើយរុំរបួសឱ្យគាត់ផងដែរ។
បុរសសាសន៍សាម៉ារីបានលើកបុរសរបួសនោះបញ្ជិះលើខ្នងលា នាំទៅផ្ទះសំណាក់ ហើយថែទាំគាត់។
ស្អែកឡើង គាត់យកប្រាក់ប្រគល់ឱ្យម្ចាស់ផ្ទះសំណាក់ ទាំងផ្ដាំថា៖
«ឥឡូវខ្ញុំត្រូវទៅហើយ។ សូមថែទាំបុរសនេះផង ប្រសិនបើអ្នកចំណាយលើសពីប្រាក់នេះ ពេលខ្ញុំត្រឡប់មកវិញ ខ្ញុំនឹងជូនបង្គ្រប់»។
បន្ទាប់ពីនិទានរឿងនេះរួចហើយ ព្រះយេស៊ូក៏បានសួរទៅបណ្ឌិតខាងវិន័យថា៖
«នៅក្នុងរឿងនេះមានមនុស្សពនាក់គឺបូជាចារ្យ បុរសលេវី និងសាសន៍សាម៉ារី។
ក្នុងចំណោមមនុស្សទាំងបីនាក់ តើលោកយល់ថា អ្នកណាជាអ្នកជិតខាងរបស់បុរសដែលធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ចោរប្លន់នោះ?»
បណ្ឌិតខាងវិន័យឆ្លើយថា៖ «គឺសាសន៍សាម៉ារីដែលមានចិត្តមេត្តាករុណា ជួយដល់គាត់»។
ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ត្រឹមត្រូវហើយ ដូច្នេះ សុំលោកអញ្ជើញទៅចុះ ហើយប្រព្រឹត្តឱ្យបានដូចអ្នកនោះទៅ»។



32

**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើមានអ្វីកើតឡើងចំពោះអ្នកដំណើរដែលចុះពីក្រុងយេរូសាឡិមទៅក្រុងយេរីខូ?

-----------------------------------------------------------------------------------

b. តើមានមនុស្សប៉ុន្មាននាក់បានដើរកាត់ជនរងគ្រោះដែលត្រូវចោរប្លន់នោះ?

-----------------------------------------------------------------------------------

c. សូមអានលូកា ១០៖៣៣-៣៥។ តើអ្នកណាបានជួយជនរងគ្រោះដែលត្រូវចោរប្លន់ ហើយគាត់បានធ្វើអ្វីខ្លះ?

-----------------------------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លូកា១០៖៣៧)

> **អ្នកនោះឆ្លើយថា គឺអ្នក១ដែលមានចិត្តអាណិតដល់គាត់នោះឯង ដូច្នេះ ព្រះយេស៊ូវមានព្រះបន្ទូលថា ទៅចុះ ចូរអ្នកប្រព្រឹត្តបែបយ៉ាងដូច្នោះដែរ។**

**សកម្មភាពទី២** សូមគូររង្វង់ចំពោះអ្វីដែលចាំបាច់សម្រាប់ការព្យាបាល និងថែទាំងដល់បុរសរងគ្រោះដោយសារចោរប្លន់ឱ្យបានជាសះស្បើយ។



